

REDD+
CAMBODIA

ព្រឹត្តិបត្តិព័ត៌មាន លេខ ១១ មករា-មីនា ឆ្នាំ២០១៧

# ក្រុមការងាររេដបូកកម្ពុជា



គណៈកម្មាធិការព្រៃសហគមន៍ដៃគូសំរោងបង្ហាញអំពីការងារគ្រប់គ្រងព្រៃសហគមន៍ដៃគូសំរោង

## បទពិសោធន៍ពីការអនុវត្តសាកល្បងគម្រោងរេដបូកនៅកម្ពុជា

បច្ចុប្បន្ននេះកម្មវិធីរេដបូក ក្រោមការគាំទ្ររបស់លេខាធិការដ្ឋានរេដបូកកំពុងអនុវត្តគម្រោងសាកល្បងរេដបូកចំនួនបីរួមមានគម្រោងបញ្ជ្រាបរេដបូកក្នុងផែនការប្រើប្រាស់ដីឃុំនិងការអភិវឌ្ឍសហគមន៍ព្រៃឈើដែលអនុវត្តដោយរដ្ឋបាលព្រៃឈើ គម្រោងរៀបចំយុទ្ធសាស្រ្តគ្រប់គ្រងតំបន់ការពារនិងអភិរក្សធនធានធម្មជាតិដែលអនុវត្តដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាននិងគម្រោងគ្រប់គ្រងនិងអភិរក្សព្រៃកោងកាងនិងព្រៃលិចទឹកដែលអនុវត្តដោយរដ្ឋបាលជលផល។ ទន្ទឹមនឹងនេះក៏មានការអនុវត្តគម្រោងរេដបូកដែលដឹកនាំដោយស្ថាប័នក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍផងដែរ ដូចជាគម្រោងសីមាក្នុងខេត្តមណ្ឌលគីរីរបស់អង្គការWCS និង គម្រោងរេដបូកនៅសហគមន៍ក្រោមជំនួយខ្នាតតូចរបស់អង្គការUNDP។

ដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍ និងមេរៀនដែលទទួលបានពីការអនុវត្តសាកល្បងគម្រោងរេដបូកនានានៅទូទាំងផ្ទៃប្រទេស លេខា

(តទៅទំព័រទី២)

## ការពង្រីកចំណេះដឹងស្តីពីរេដបូកដល់សហគមន៍មូលដ្ឋាន

ក្រុមប្រឹក្សាយោបល់រេដបូកកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់កម្មវិធីរេដបូកទៅនឹងសហគមន៍មូលដ្ឋាន អង្គការក្រៅ រដ្ឋាភិបាលសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដោយបានជួយនាំយកព័ត៌មានពីមូលដ្ឋានមកចែករំលែកនៅថ្នាក់ជាតិ និងបញ្ជូនព័ត៌មានត្រលប់ទៅមូលដ្ឋាន ឬអ្នកពាក់ព័ន្ធវិញ។ ក្រុមប្រឹក្សាយោបល់រេដបូកតែងតែជួបប្រជុំសមាជិកក្រុមចំនួន ៤ដងក្នុងមួយឆ្នាំដើម្បី ចែករំលែកព័ត៌មានស្តីពីរេដបូក ដែលគិតមកដល់ពេលនេះមានចំនួន ១៧ ដងរួចមកហើយ។

ក្នុងកិច្ចប្រជុំលើកទី១៧ របស់ក្រុមប្រឹក្សាយោបល់រេដបូកដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៧ សមាជិកក្រុមបានពិភាក្សាលម្អិតលើផែនការលើកកម្ពស់ចំណេះដឹង និងចែករំលែកព័ត៌មានអំពីកម្មវិធីរេដបូកដែលខ្លួនទទួលបានពីថ្នាក់ជាតិទៅចែករំលែកដល់សហគមន៍មូលដ្ឋាន។ យោងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាយោបល់នឹងចុះចែករំលែកព័ត៌មានស្តីពីរេដបូកដល់

(តទៅទំព័រទី៣)

តពីទំព័រទី១...

## បទពិសោធន៍ពីការអនុវត្តសាកល្បង...

ធិការដ្ឋានរេដបូកបានរៀបចំសិក្ខាសាលានាថ្ងៃទី២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១៧ នៅខេត្តសៀមរាប ដោយមានអ្នកចូលរួមសរុបចំនួន ១១៥ នាក់ (ស្ត្រី២៥នាក់) ដែលជាអ្នកចូលរួមអនុវត្ត និងទទួលផលពី ការអនុវត្តសាកល្បងគម្រោងរេដបូកមកពីបណ្តាខេត្តចំនួន ១០។ តាមរយៈការចូលរួមធ្វើបទបង្ហាញ និងកិច្ចពិភាក្សាយ៉ាងផុលផុស សិក្ខាសាលាទទួលបានបទពិសោធន៍ និងមេរៀនសំខាន់ៗដូចខាង ក្រោម៖

១. ការរៀបចំឲ្យមានផែនការប្រើប្រាស់ដី ការបែងចែក និងកំណត់ព្រំប្រទល់ដីឲ្យបានច្បាស់លាស់ រវាងដីព្រៃសហគមន៍ ដីព្រៃការពារ ដីលំនៅដ្ឋាន ដីកសិកម្ម និងដីបម្រុងទុកសម្រាប់ការអភិវឌ្ឍ នានា ជួយឲ្យសហគមន៍ និងអាជ្ញាធរ មានមូលដ្ឋានច្បាស់លាស់ក្នុងការការពារការទន្ទ្រានចូលដីព្រៃឈើ។ ប៉ុន្តែកត្តាដែលកំពុងប្រឈមគឺសហគមន៍មួយចំនួននៅមិនទាន់ទទួលបានសេចក្តីប្រកាសទទួលស្គាល់ស្របច្បាប់នៅឡើយ  ហើយតំបន់មួយចំនួននៅមិនទាន់មានផែនការប្រើប្រាស់ដីឃុំ  ដែលជាហេតុនាំឲ្យមានការលំបាកដល់ការការពារ និងគ្រប់គ្រងធនធានព្រៃឈើ។

២.ការពង្រឹងកិច្ចសហការយាមល្បាតដោយមានការចូលរួមពីសហគមន៍ អង្គភាពជំនាញ និងអាជ្ញាធរមូលដ្ឋានរួមទាំងកម្លាំងប្រដាប់អាវុធ បានធ្វើឲ្យបទល្មើសត្រូវបានអន្តរាគមន៍ទាន់ពេលវេលា។ ទោះជាយ៉ាងណាក៏ដោយ កង្វះខាតចំនួនសមាជិក ក្រុមល្បាត និងសមត្ថភាពក្នុងការរាយការណ៍និងការរៀបចំរបាយការណ៍ តម្រូវឲ្យមានការកែលម្អបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពការងារឲ្យកាន់តែល្អប្រសើរឡើង។

៣.ការគាំទ្រដល់ការបង្កើតជម្រើសមុខរបរដើម្បីបង្កើនចំណូលដល់សហគមន៍ អាចជួយគាំទ្រនិរន្តរភាពសកម្មភាពល្បាតព្រៃ។ សកម្មភាពដែលអាចរកចំណូលជួយដល់ សហគមន៍ និងជួយដល់ការពារព្រៃឈើមានដូចជាការបង្កើតតំបន់អេកូទេសចរណ៍ និងការកែច្នៃអនុផលព្រៃឈើ ចំណែកមុខរបរដែល អាចរកចំណូល បន្ថែមក្រៅពីព្រៃឈើក៏ទទួលបានការគាំទ្រផងដែរ។ ជាក់ស្តែងគម្រោង



ការពិភាក្សាតាមក្រុមក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តសាកល្បងគម្រោងរេដបូក



ក្រុមយាមល្បាតព្រៃសហគមន៍បង្ហាញវល្លិ៍ទឹកដែលអ្នកដើរព្រៃអាចបរិភោគបានពេលមានតម្រូវការចំបាច់

រេដបូកដោយសហគមន៍ (CBR+) នៅខេត្តរតនគីរីបានឧបត្ថម្ភ កសាងស្ថានីយ៍ផលិតថាមពលពីពន្លឺព្រះអាទិត្យដើម្បីសាកអាគុយបានជួយឲ្យសហគមន៍ទទួលបាន ចំណូលសម្រាប់គាំទ្រសកម្មភាពល្បាត។

៤. ការផ្តល់ជម្រើសថាមពល និងការសន្សំសំចៃអុស អាចជួយកាត់បន្ថយជាអតិប្បរមានូវសម្ពាធនៃការប្រើប្រាស់ព្រៃឈើដូចជាការប្រើប្រាស់ឡជីវស្ម័ន និងចង្ក្រានសន្សំសំចៃអុស ដែលកំពុងទទួលបានការគាំទ្រច្រើនពីប្រជាសហគមន៍  ប៉ុន្តែការបង្កើតឡជីវឧស្ម័នទាមទារនូវលក្ខខ័ណ្ឌបច្ចេកទេស និងតំរូវការថវិកាមួយចំនួនដែលប្រជាសហគមន៍ត្រូវការជំនួយបន្ថែមពីគម្រោង និងអ្នកពាក់ព័ន្ធនានា។

៥. ការលើកកម្ពស់ចំណេះដឹងអាចជួយឲ្យសហគមន៍មានការយល់ដឹងច្រើនពីផលប្រយោជន៍ព្រៃឈើ ភាពអវិជ្ជមាន នៃការបាត់បង់ព្រៃឈើ  និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងសហគមន៍របស់ខ្លួន។ ប៉ុន្តែដើម្បីពង្រីកចំណេះដឹង និងបទពិសោធន៍គួររៀបចំឲ្យមានកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ជាមួយសហគមន៍ដែលមកពីតំបន់ផ្សេងៗ ដើម្បីស្វែងយល់បន្ថែមពីរបៀបគ្រប់គ្រងព្រៃឈើការប្រកបរបរចញ្ចឹមជីវិត ការរកចំណូល សម្រាប់គាំទ្រការការពារព្រៃឈើ របៀបក្នុងការដឹកនាំសហគមន៍ ការចរចារ និងការដោះស្រាយជម្លោះជាដើម។ល។

គម្រោងសាកល្បងរេដបូក បាននិងកំពុងជួយគាំទ្រដល់ការអនុវត្តសកម្មភាពជាច្រើនក្នុងចំណុចខាងលើ ហើយបទពិសោធន៍ និងមេរៀនដែលទទួលបានពីសិក្ខាសាលានេះ នឹងជួយដល់ការរៀបចំផែនការសកម្មភាព ដើម្បីបន្តការសហការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានក្នុងការកាត់បន្ថយការបាត់បង់ និងរេចរិលព្រៃឈើ។ បទពិសោធន៍ និងមេរៀនដែលទទួលបានទាំងនេះក៏ជាធាតុចូលសំខាន់សម្រាប់ការកសាងផែនការយុទ្ធសាស្រ្តរេដបូកជាតិ និងផ្តល់ជាអនុសាសន៍ដល់ការរៀបចំគោលនយោបាយគ្រប់គ្រងព្រៃឈើនៅថ្នាក់ជាតិផងដែរ។

សហ គមន៍មូលដ្ឋានចំនួន ១២ កន្លែង ដែលក្នុងនោះមានសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍ជនជាតិដើមភាគតិច ដោយសង្ឃឹមថាប្រជាសហគមន៍នឹងទទួលបានចំណេះដឹងបន្ថែមស្តីពីវិធានការរេដបូកក្នុងការកាត់បន្ថយការបាត់បង់ និងរេចរិលព្រៃឈើ ហើយនឹងជួយផ្សព្វផ្សាយបន្តដល់សហគមន៍របស់ពួកគាត់។

បន្ថែមពីលើគោលបំណងនេះ ក្រុមប្រឹក្សាយោបល់រេដបូកនឹងចាប់យកឱកាសពង្រឹងយន្តការលំហូរព័ត៌មានដោយបង្ហាញពីវិធីសាស្រ្តដែលប្រជាសហគមន៍អាចផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាយោបល់ និងវិធីសាស្រ្តទទួលព័ត៌មានត្រឡប់មកវិញ។

ផែនការនេះនឹងចាប់ផ្តើមអនុវត្តចាប់ពីចុង ខែឧសភា ដល់ ខែកក្កដា ឆ្នាំ២០១៧។



លោក ម៉ែន ប៉ាក់ (រូបកណ្តាល អាវពណ៌ស) តំណាងក្រុមប្រឹក្សាយោបល់រេដបូក និងជាតំណាងជនជាតិដើមភាគតិចសំណេះសំណាល ជាមួយប្រជាសហគមន៍ ដើម្បីស្វែងយល់ ពីបទពិសោធន៍របស់សហគមន៍ពពេល ក្នុងការការពារព្រៃឈើ

## ទស្សនកិច្ចសិក្សាស្វែងយល់ពីគម្រោងសាកល្បងរេដបូកនៅមូលដ្ឋាន

ដើម្បីស្វែងយល់ពីការអនុវត្តសាកល្បងគម្រោងរេដបូកនៅថ្នាក់ក្រោមជាតិកាលពីថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៧ ប្រធានប្រចាំប្រទេសនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លោក Nick Beresford រួមជាមួយលេខាធិការដ្ឋានរេដបូក បានចុះជួបមន្ត្រីគម្រោង និងប្រជាសហគមន៍ដែលចូលរួមអនុវត្តគម្រោងបញ្ជ្រាបរេដបូកក្នុងផែនការប្រើប្រាស់ដីឃុំក្នុងឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលគម្រោងនេះអនុវត្តដោយរដ្ឋបាលព្រៃឈើ។

បទពិសោធន៍សំខាន់ៗដែលទទួលបានពីគម្រោងនេះគឺ៖ ទី១. ការបញ្ជ្រាបរេដបូកក្នុងផែនការប្រើប្រាស់ដីឃុំ ដែលផែនការនេះធ្វើឡើងសម្រាប់គ្រប់គ្រងការប្រើប្រាស់ដីឃុំសម្រាប់ការធ្វើកសិកម្ម កសាងលំនៅដ្ឋាន ព្រៃសហគមន៍ និងការអភិវឌ្ឍផ្សេងៗ ដោយធានាដល់ស្ថេរភាពនៃការអភិវឌ្ឍដីឃុំ និងនិរន្តភាពនៃការប្រើប្រាស់ធនធានធម្មជាតិ។ ទី២. គឺការលើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ និងប្រជាសហគមន៍ក្នុងការកំណត់បុព្វហេតុនៃការបាត់បង់និងរេចរិលព្រៃឈើ និងការចាត់វិធានការក្នុងការកាត់បន្ថយបុព្វហេតុទាំងនោះ។ ទី៣. គម្រោងបានជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំក្នុងដំណើរការស្នើសុំសេចក្តីប្រកាសជាផ្លូវការដើម្បីទទួលស្គាល់ព្រៃសហគមន៍ដៃគូសំរោងដោយស្របច្បាប់។ និងទី៤. គឺការលើកកម្ពស់ជីវភាពសហគមន៍ និងការផ្តល់ជម្រើសថាមពលដើម្បីកាត់បន្ថយការប្រើប្រាស់អុសធ្យូងដែលជាសំពាធលើការបាត់បង់ធនធានធម្មជាតិ។

ក្រុមការងារសង្កេតឃើញថា អ្វីដែលជាលក្ខណៈពិសេសរបស់ឃុំនេះគឺការបង្កើតឲ្យមានផែនការប្រើប្រាស់ដីឃុំច្បាស់លាស់ និងការគ្រប់គ្រងព្រៃសហគមន៍ដៃគូដោយក្រុមប្រឹក្សាឃុំ ក្រោមការសហការយ៉ាងជិតស្និតជាមួយប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ទាំងនេះបានជម្រុញឲ្យប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើកាន់តែមានភាពប្រសើរជាងមុន។ នេះគឺជាបទពិសោធន៍ដ៏ល្អមួយដែលអាចយកទៅបញ្ជ្រាបក្នុងការរៀបចំផែនការសកម្មភាពរបស់យុទ្ធសាស្រ្តរេដបូកជាតិ។



ក្រុមប្រឹក្សាឃុំសំរោងចែករំលែកបទពិសោធន៍ក្នុងការគ្រប់គ្រប់ព្រៃសហគមន៍ដៃគូ



Nick Beresford សាកសួរប្រជាសហគមន៍ ពីប្រសិទ្ធភាពនៃការប្រើប្រាស់ចង្ក្រានឃ្លាសពីឡជីវឧស្ម័ន

# ភាពជោគជ័យរបស់សហគមន៍ក្នុងការការពារព្រៃកោងកាង



"សហគមន៍ខ្ញុំពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ រួមមានផលនេសាទ និងព្រៃឈើ សម្រាប់បំពេញតំរូវការប្រចាំថ្ងៃ...ពួកយើងមិនចាំបាច់ចំណាយលុយច្រើនទេក្នុងការទិញត្រីសាច់....បើសិនជាថ្ងៃណាមួយ ព្រៃឈើត្រូវបាត់បង់ ពួកយើងច្បាស់ជាជួបនឹងផលលំបាកយ៉ាងខ្លាំង។" លោក រៀម ម៉ូសារី ប្រធានសហគមន៍នេសាទស្រុកព្រៃនប់ ២

ពេលព្រឹកព្រលឹមមួយ នៅក្បែរវារីវប្បកម្មរបស់សហគមន៍នេសាទព្រៃនប់២ លោក រៀម ម៉ូសារី ប្រធានសហគមន៍កំពុងចែករំលែកបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើក្នុងសហគមន៍។

សហគមន៍នេសាទព្រៃនប់២ គ្រប់ដណ្តប់តំបន់ដែលមានផ្ទៃដីសរុបចំនួន ៤៥០០ ហិកតា ដែលក្នុងនោះមានព្រៃកោងកាងចំនួន ៦៥០ ហិកតា។ សហគមន៍នេះសំបូរដោយធនធានធម្មជាតិដែលផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាសហគមន៍ និងអាចទាក់ទាញភ្ញៀវទេសចរណ៍ដែលចូលចិត្តការកំសាន្តបែបធម្មជាតិហើយសហគមន៍នេះក៏ឋិតនៅជិតផ្សារ និងតំបន់សេវាសាធារណៈផងដែរ។

ក្នុងឆ្នាំ ២០១៦ សហគមន៍នេសាទនេះបានប្រើប្រាស់មធ្យោបាយ និងយុទ្ធសាស្ត្រយ៉ាងច្រើនដើម្បីការពារព្រៃសហគមន៍ពីការទន្ទ្រានចូលដោយអ្នកមានអំណាចដែលប៉ុនប៉ងកាប់ឆ្ការដីចំនួន ៤៥ហិកតា ដើម្បីបំប្លែងទៅជាចំការដំណាំ។

ជាដំបូងសហគមន៍បានរៀបចំពាក្យបណ្តឹង ដោយមានការគាំទ្រពីខ័ណ្ឌរដ្ឋបាលជលផល ព្រមទាំងមានការសហការផ្ទៃក្នុងដោយសមាជិកទាំងអស់របស់សហគមន៍បានរួបរួមគ្នាផ្តិតមេដៃដើម្បីដាក់ពាក្យបណ្តឹងតវ៉ាទៅអាជ្ញាធរដែលមានសមត្ថកិច្ចដើម្បីដោះស្រាយការប៉ុនប៉ងកាប់ឆ្ការដីព្រៃកោងកាងក្នុងដែនសហគមន៍នេសាទ។

".....ជិវិតរបស់យើងគឺពឹងផ្អែកលើធនធានធម្មជាតិក្នុងសហគមន៍ ដូចនេះយើងត្រូវខិតខំប្រឹងប្រែងថែរក្សា និងការពារធនធានទាំងនេះឲ្យបាន និងព្យាយាមប្រើប្រាស់គ្រប់មធ្យោបាយដើម្បីទប់ស្កាត់រាល់ការទន្ទ្រាននានា។"

គួរបញ្ជាក់ថា មុននឹងមានករណីនេះកើតឡើង សហគមន៍ទទួលបានការចុះបញ្ជីដោយមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយមានប្រកាសជាផ្លូវការដែលបញ្ជាក់ពីទំហំដីនិងព្រំប្រទល់ដីសហគមន៍ និងមានសិទ្ធពេញលេញក្នុង ការគ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់សហគមន៍ ដូចនេះសហគមន៍មានសិទ្ធក្នុងការការពារព្រៃសហគមន៍ពីការឈ្លានពានរបស់អ្នកខាងក្រៅ។

ដើម្បីទទួលបានការអន្តរាគមន៍បន្ថែមពីអ្នកពាក់ព័ន្ធ សហគមន៍បានទំនាក់ទំនងជាមួយក្រុមអ្នកសារព័ត៌មាន ដើម្បីចុះមកយកព័ត៌មានពីករណីបំពាននេះ។ ក្រោយមកព័ត៌មានរបស់សហគមន៍ក៏ត្រូវបានផ្សព្វផ្សាយ និងក្លាយជាចំណាប់អារម្មណ៍ដ៏សំខាន់មួយរបស់អាជ្ញាធរថ្នាក់ខេត្ត និងស្ថាប័នថ្នាក់ជាតិ ដោយទទួលបានការចុះមកស៊ើបអង្កេតផ្ទាល់ និងដាក់ចំណាត់ការភ្លាមៗ។ ទីបំផុតសហគមន៍ក៏ទទួលបានជោគជ័យលើបណ្តឹងនេះដោយទទួលបានដីព្រៃចំនួន៤៥ហិកតាត្រឡប់មកវិញ។

ទាំងនេះសបញ្ជាក់ឲ្យឃើញថាភាពជោគជ័យនេះគឺកើតចេញពីភាពសាមគ្គីភាពផ្ទៃក្នុងរបស់សហគមន៍ និងការសហការខ្ពស់ជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់។

ទោះជាយ៉ាងណាក៏ដោយសហគមន៍នេសាទនេះនឹងនៅតែបន្តការពារព្រៃសហគមន៍ឲ្យបានគង់វង្ស ហើយក្នុងនាមជាអ្នកប្រើប្រាស់ និងនៅជាប់លាប់ជាមួយធនធានធម្មជាតិដោយផ្ទាល់ សហគមន៍ តែងមានភារកិច្ចឃាមល្បាតព្រៃឈើ និងរាយការណ៍រាល់បទល្មើសទៅអាជ្ញាធរមូលដ្ឋានដើម្បីធ្វើអន្តរាគមន៍ទាន់ពេលវេលា។

កម្មវិធីរេដបូកកម្ពុជា ក្រោមការគាំទ្ររបស់អង្គការ យូ អិន ឌី ភី និងអង្គការភាពជាដៃគូកាបូនព្រៃឈើ ក្រោមការសហការយ៉ាងជិតស្និតជាមួយរដ្ឋបាលជលផល កំពុងផ្តល់ការគាំទ្រដល់សហគមន៍ព្រៃនប់ ២ក្នុងការកាត់បន្ថយការបាត់បង់ និងរេចរិលព្រៃឈើ តាមរយៈការពង្រឹងសមត្ថភាពគ្រប់គ្រងព្រៃឈើ ល្បាតព្រៃ លើកកម្ពស់ចំណេះដឹងជាដើម។ល។ បន្ថែមពីនេះគម្រោង កំពុងគាំទ្រដល់ការសិក្សាអំពីជម្រើសជីវភាពពីវិស័យទេសចរណ៍ដើម្បីរកចំណូលជួយសហគមន៍ក្នុងការបន្តការការពារធនធានធម្មជាតិ។

**លេខាធិការដ្ឋានរេដបូក**

អគារលេខ ៤០ ផ្លូវនរោត្តម សង្កាត់ផ្សារកណ្តាល ២

ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២២៤ ២៥១

ទូរសារៈ redd.secretariat@cambodia-redd.org

Facebook: Cambodia REDD+ National Program